LOS ANGELES COUNTY
SUBSTANCE USE
DISORDER SPECIALTY
CARE PLAN

CAMBODIAN

# សៀវភៅណែនាំសំរាប់អ្នកជម្ងឺនិងវីដេអូបង្ហាញការណែនាំ

## តើអ្វីទៅជាសៀវភៅណែនាំសំរាប់អ្នកជម្ងឺនិងវីដេអូបង្ហាញការណែនាំ

សៀវភៅណែនាំសម្រាប់អ្នកជម្ងឺផ្តល់ជូននូវការពន្យល់ពេញលេញអំពីអត្ថប្រយោជន៍នៃការព្យាបាលការប្រើប្រាស់សារធាតុញៀនមិនប្រក្រតីក្រោមការគ្រប់គ្រងរបស់ផែនការជំនាញថែទាំការប្រើប្រាស់សារធាតុញៀនខុសប្រក្រតីខោនធីឡូសអេនចេលែស (ឬ “ផែនការខោនធី”) រួមមាន៖ អ្នកដែលមានសិទ្ធិទទួល និងសេវាកម្មអ្វីខ្លះដែលមិនគិតថ្លៃ។ សៀវភៅណែនាំសម្រាប់អ្នកជម្ងឺបោះពុម្ពខ្នាតធំដោយកតគិតថ្លៃ និងជាភាសាដទៃទៀត ដែលអាចរកបានពីអ្នកផ្តល់សេវាព្យាបាលរបស់អ្នក ឬអាចទាញយកបានពី http://publichealth.lacounty.gov/sapc/ ។ វីដេអូបង្ហាញការណែនាំ

អ្នកជម្ងឺធ្វើអោយមានភាពងាយស្រួលដើម្បីយល់សេចក្តីសង្ខេបនៃសៀវភៅណែនាំសំរាប់អ្នកជម្ងឺនិងពិពណ៌នាអំពីអត្ថប្រយោជន៍សំខាន់ៗសម្រាប់អ្នកស្ថិតនៅក្រោមផែនការខោនធី។

## សិទ្ធិរបស់អ្នក

ក្នុងនាមជាសមាជិកដែលមានសិទ្ធិពីផែនការខោនធី អ្នកមានសិទ្ធិទទួលសេវាកម្មដែលចាំបាច់ក្នុងការព្យាបាលការប្រើប្រាស់សារធាតុញៀន ។ អ្នកក៏មានសិទ្ធិ៖

- **មិនមានការរំលោភបំពានដោយពាក្យសំដី លើផ្លូវអារម្មណ៍ ឬផ្លូវភេទ ឬរូបរាងកាយ**
- **ការពារព័ត៌មានសុខភាពរបស់អ្នកឱ្យ និងរក្សាភាពឯកជន**
- **ចូលរួមសំរេចចិត្តទាក់ទងនឹងការព្យាបាលរបស់អ្នក រួមទាំងសិទ្ធិក្នុងការបដិសេធការព្យាបាល**
- **ទទួលព័ត៌មានអំពីជម្រើសនៃការព្យាបាលដែលមាន និងជម្រើសផ្សេងទៀតតាមវិធីដែលងាយស្រួលសម្រាប់អ្នក**
- **ដាក់បណ្តឹងតវ៉ា (ឬបណ្តឹងឧទ្ធរណ៍)**
- **មានសិទ្ធិអនុវត្តសិទ្ធិទាំងនេះដោយគ្មានផលប៉ះពាល់អវិជ្ជមានដល់របៀបដែលអ្នកត្រូវបានគេព្យាបាល**

## សេចក្តីថ្លែងការពីការមិនរើសអើង

នាយកដ្ឋានសុខភាពសាធារណៈខោនធីឡូសអេនចេលែស, Substance Abuse Prevention and Control (SAPC), ព្រមទាំងអ្នកផ្តល់សេវាព្យាបាលជាប់កិច្ចសន្យារបស់ខ្លួន អនុវត្តតាមច្បាប់សិទ្ធិស៊ីវិលនិងសហព័ន្ធដែលមិនមានការរើសអើង ។ អ្នកអាចរាយការណ៍អំពីការរំលោភបំពាននានាទៅកាន់ផែនការខោនធី ដោយប្រើព័ត៌មានទំនាក់ទំនងដែលមាននៅទំព័របន្ទាប់។

## សេវាកម្មព្យាបាលដោយមិនគិតថ្លៃ

ក្នុងនាមជាសមាជិកដែលមានសិទ្ធិពីផែនការខោនធី អ្នកផ្តល់សេវាព្យាបាលរបស់អ្នកមិនអាចស្នើសុំឱ្យអ្នកបង់ប្រាក់ដើម្បីទទួលសេវាកម្មណាមួយដែលបានពិពណ៌នានៅក្នុងសៀវភៅណែនាំអ្នកជម្ងឺរបស់អ្នកទេ។ នេះមានន័យថា:

- មិនគិតថ្លៃ
- មិនមានប្រាក់កក់
- មិនគិតថ្លៃអ្វីទាំងអស់ លើកលែងតែមានតំរូវការពីអត្ថប្រយោជន៍ Medi-Cal របស់អ្នក

## បណ្ដឹងតវ៉ា / បណ្ដឹងឧទ្ធរណ៍ និងសំណង

ប្រសិនបើអ្នកមានអារម្មណ៍ថាអ្នកត្រូវបានគេធ្វើបាប ឬបដិសេធសេវាកម្មដែលបានកំណត់នៅក្នុងសៀវភៅណែនាំសំរាប់អ្នកជម្ងឺអ្នកអាចដាក់ពាក្យបណ្ដឹងបាន។ ប្រសិនបើអ្នកមិនយល់ស្របនឹងការសម្រេចចិត្តដែលបានធ្វើឡើងលើការព្យាបាលរបស់អ្នក អ្នកអាចប្ដឹងឧទ្ធរណ៍ចំពោះការសម្រេចចិត្តនេះបាន។

ដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងតវ៉ានឹងមិនជះឥទ្ធិពលអវិជ្ជមានដល់ការព្យាបាលរបស់អ្នក ឬសេវាកម្មព្យាបាលដែលអ្នកទទួលបានឡើយ។ អ្នកអាចដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងតវ៉ាជាមួយគំរោងខោនធី ឬបណ្ដាញអ្នកផ្ដល់សេវា តាមរយៈអ៊ីម៉ែល ផ្ញើតាមប្រៃសណីយ៍ តាមទូរស័ព្ទ ឬទូរសារ។

## ព័ត៌មានទំនាក់ទំនង

### ផែនការខោនធី

Department of Public Health, Substance Abuse Prevention and Control
1000 South Fremont Avenue, Building A-9 East, 3rd Floor
Alhambra, California 91803
SAPCMonitoring@ph.lacounty.gov
(Phone) 1-888-742-7900 | (Fax) 1-626-458-6692

អាចរកបែបបទបាននៅ៖
http://publichealth.lacounty.gov/sapc/PatientPublic.htm

### ព័ត៌មានទំនាក់ទំនងរបស់អ្នកផ្ដល់សេវាព្យាបាល

Enter Agency Name

Enter Contact (Division or Person)

Enter Email Address

Enter Street Address

Enter City, State, Zip

Enter Agency Website OR SAPC Website

(Phone) 1-000-000-0000 (Fax) 1-000-000-0000

អាចរកបែបបទបាននៅ៖

Enter Agency Website OR SAPC Website

## ទទួលស្គាល់

(1) ខ្ញុំបានទទួលឯកសារថតចម្លងមួយច្បាប់ ព្រមទាំង

(2) ខ្ញុំត្រូវបានគេជូនដំណឹងអំពីអត្ថប្រយោជន៍នៃការព្យាបាលរបស់ខ្ញុំក្រោមផែនការខោនធី (សូមគូសលើអ្វីទាំងអស់ដែលបានអនុវត្ត)៖

- ○ ខ្ញុំបានមើលវីដេអូបង្ហាញការណែនាំអ្នកជម្ងឺ
- ○ ខ្ញុំត្រូវបានគេបង្ហាញពីរបៀបស្វែងរកសៀវភៅណែនាំអ្នកជម្ងឺនៅលើគេហទំព័ររបស់ផែនការខោនធី
- ○ អ្នកផ្ដល់សេវាព្យាបាលរបស់ខ្ញុំបាននិយាយជាមួយខ្ញុំអំពីអត្ថប្រយោជន៍នៅក្នុងសៀវភៅណែនាំអ្នកជម្ងឺ

អ្នកជម្ងឺ:

ឈ្មោះបោះពុម្ព: ហត្ថលេខា កាលបរិច្ឆេទ (ខខ/ថថ/ឆឆឆឆ):

**Provider Staff:**

Print Name Signature Date (mm/dd/yyyy)

Updated 01.2020